ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ៧៦៦/០៨-៨-២០១២

**សាលដីកា**

លេខ១៧ក្រVIយ

ចុះថ្ងៃទី២១-៥-២០១៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី១០-៥-២០១៣ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

**លោក [redacted] ប្រធាន**

**លោក [redacted] ចៅក្រមប្រឹក្សា**

**លោក [redacted] ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted]**

**ក្រឡាបញ្ជី**

**លោកស្រី ប៉េស រីណា**

ដើម្បីជំនុំជំរះបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ៧៦៦ចុះថ្ងៃទី០៨-៨-២០១២រវាង៖

**-ជនជាប់ចោទឈ្មោះ** [redacted]**ស្រីម៉ៅ(ដើមបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៣៨ ឆ្នាំ ជាតិខ្មែរ មុខរបរជាងអ៊ុតសក់ កើតនៅសង្កាត់លេខ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្ទ[redacted] សង្កាត់ផ្សារដេប៉ូ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted](រ) ប្តីឈ្មោះ[redacted](លែងលះ) មានកូន៣នាក់ ទោសពីមុនគ្មាន។ឃុំខ្លួន១៥-១១-២០១១។

**ត្រូវចោទពីបទ៖ «រំលោភលើសេចក្តីទុកចិត្ត »**ប្រព្រឹត្តនៅរាជធានីភ្នំពេញ





Scanned with CamScanner

កាលពីថ្ងៃទី០២-៨-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

.**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ហ្វូត(ចុងបណ្តឹងឧទ្ធរណ៍)** ភេទប្រុស អាយុ៧៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១១៦E០ ផ្លូវលេខ២៩៨ ក្រុម៧ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

** បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៧-២០១២របស់ឈ្មោះ[redacted] ស្រីម៉ៅ មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៩«ច»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**<u>ដំណើររឿងមានដូចតទៅ៖</u>**

កាលថ្ងៃទី០២-៨-២០១១ឈ្មោះ[redacted] ស្រីម៉ៅ បានមកជួលឡានរបស់ជនរងគ្រោះឈ្មោះ[redacted]ហ្វូត ១គ្រឿងម៉ាកHONDA CRVពណ៌ខ្មៅ សេរី១៩៩៣ពាក់ស្លាកលេខ2J 5692 ក្នុងតំលៃ៤០០$(បួនរយដុល្លាអាមេរិច)ក្នុង១ខែ។ក្រោយពីបានឡានរួចឈ្មោះ[redacted] ស្រីម៉ៅ ក៏យកឡាននោះទៅបញ្ចាំនៅកាស៊ីណូណាហ្គាវើលបាត់ ដោយពុំបានយកឡាននោះមកវិញទេ រហូតដល់ថ្ងៃនេះ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ២៩«ច»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីដូចតទៅ៖

១.ផ្តន្ទាទោសឈ្មោះ[redacted]ស្រីម៉ៅ ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ (មានសាវតាខាងលើ)ដាក់ពន្ធនាគារចំនួន០៨ខែ គិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី០២.៨.២០១១ ពីបទរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២-៨-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យឈ្មោះ[redacted] ស្រីម៉ៅ សងសំណងឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩.០០០$(ប្រាំបួនពាន់ដុល្លាអាមេរិច)ការទាមទារលើសពីនេះត្រូវលើកចោល។

៣.សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥.៦.២០១២ ចំពោះមុខជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

ចៅក្រមអានរបាយការណ៍.

ជនជាប់ចោទឈ្មោះ[redacted]ស្រីម៉ៅ ឆ្លើយថា៖ ខ្លួនអាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរជាងអ៊ុតសក់ កើតនៅសង្កាត់លេខ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្ទះ [redacted]ក្រុម៧ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted] (រ) ប្តីឈ្មោះ[redacted] (លែង



Scanned with CamScanner

ល:) មានកូន៣នាក់ ទោសពីមុនគ្មាន។ខ្លួនទទួលស្គាល់កំហុសរបស់ខ្លួន តែខ្លួនប្តឹងឧទ្ធរណ៍ព្រោះតុលាការរាជធានីភ្នំពេញសំរេចឲ្យខ្លួនសងសំណងដល់ទៅចំនួន៩.០០០$ (ប្រាំបួនពាន់ដុល្លាអាមេរិច)ច្រើនពេក ឡាននោះមានតំលៃត្រឹមតែ៥.០០០$(ប្រាំពាន់ដុល្លាអាមេរិច)ប៉ុណ្ណោះ ហើយម្ចាស់ឡានបានយកឡានវិញហើយ។សំណូមពរសុំតុលាការសំរេចបន្ធូរបន្ថយសំណងផង។

តំណាងមហាអយ្យការសន្និដ្ឋានថា:ជនជាប់ចោទឈ្មោះ [redacted] ស្រីមៅ បានទទួលស្គាល់នូវកំហុសរបស់ខ្លួន ប៉ុន្តែសុំឲ្យសាលាឧទ្ធរណ៍ពិចារណាបន្ធូរបន្ថយប្រាក់សំណងដែលត្រូវសងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី។មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស្រីមៅ ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២-៨-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។សុំសភាព្រហ្មទណ្ឌសំរេចតាមច្បាប់។

ក្រោយពីបានស្តាប់ចំលើយជនត្រូវចោទ.

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៧-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីមៅ ប្តឹង ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២៩«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

២.ជនជាប់ចោទឈ្មោះ [redacted] ស្រីមៅ បានទទួលស្គាល់នូវកំហុសរបស់ខ្លួន ប៉ុន្តែសុំឲ្យសាលាឧទ្ធរណ៍ពិចារណាបន្ធូរបន្ថយប្រាក់សំណងដែលត្រូវសងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំណុចនេះពុំមានភស្តុតាងណាដើម្បីឲ្យតុលាការពិចារណាឡើយ។

៣.មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស្រីមៅ ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២-៨-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

៤.សាលក្រមព្រហ្មទណ្ឌលេខ២៩«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញសំរេចសេចក្តីមានលក្ខណ:ត្រឹមត្រូវតាមអង្គហេតុ និង អង្គច្បាប់ហើយ គួរតំកល់ទុកជាបានការ។

ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៧-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីមៅ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។



Scanned with CamScanner

២.តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៩«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

៣.បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២១-៥-២០១៣ ចំពោះមុខជនជាប់ចោទ និង ចាត់ទុកចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមត្រឹមត្រូវតាមច្បាប់.**

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា [redacted] [redacted]. [redacted] [redacted]

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍,ថ្ងៃទី ២៤ ខែ ០៦ ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]





Scanned with CamScanner